ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ២១៦៣ "ព"

ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ៨២៤៥

ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ ៦០៤៩

ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ៧២០

ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

បានបើកសវនាការសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ ពេលព្រឹក នៅសាលសវនាការទី៩ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៨២៤៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរអ្នកចាក់ហ្គេមនៅកំពង់សោម នៅលីវ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ[redacted] "រស់" ជានីតិជន ទោសពីមុន "គ្មាន"។ (ក្នុងឃុំ)

ទីកន្លែងកំណើតនៅភូមិ[redacted]ខេត្តតាកែវ។

លំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិអញ្ចាញ សង្កាត់[redacted] ក្រុង[redacted] ខេត្តសៀមរាប។

ដោយមានលោក[redacted] សុខា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ឃាត់ខ្លួននៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៣៨១៣ "ឆ" ដ.ឃ.ដ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០។ (ម១)

ជាប់ចោទពីបទ ប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល និងគំរាមកំហែងហែកកេរ្តិ៍ ប្រព្រឹត្តនៅលើបណ្តាញសង្គមហ្វេសប៊ុក (Messenger របស់ជនរងគ្រោះ) កាលពីអំឡុងឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០២, មាត្រា៣៧២ និងមាត្រា៣៧៣ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ឡែន ភេទស្រី អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ[redacted]ខេត្ត[redacted] ប្រទេសជប៉ុន។

ដោយមានលោកស្រី[redacted]ស៊ីវិន ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៩ ជនរងគ្រោះឈ្មោះ[redacted]ឡែន ភេទស្រី អាយុ១៩ឆ្នាំ បានស្គាល់ជាមួយឈ្មោះ [redacted]ភក្តី ភេទប្រុស អាយុ១៩ឆ្នាំ តាមរយៈបណ្តាញសង្គមហ្វេសប៊ុក និងបានស្រឡាញ់គ្នា ហើយបានរួមរស់នៅជាមួយគ្នាដូចប្តីប្រពន្ធ។ អំឡុងពេលរួមរស់នៅជាមួយគ្នា ជនជាប់ចោទឈ្មោះ[redacted] ភក្តី តែងតែលួចថតវីដេអូ និងរូបភាពអាក្រាតរបស់ជនរងគ្រោះដោយមិនបានឱ្យជនរងគ្រោះដឹងខ្លួនឡើយ។ លុះមកដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ ជនរងគ្រោះបានប្រឡងជាប់ការងារនៅប្រទេសជប៉ុន និងបានធ្វើដំណើរទៅបម្រើការងារនៅប្រទេសជប៉ុន។ អំឡុងពេលដែលជនរងគ្រោះធ្វើការងារនៅឯប្រទេសជប៉ុន ជនជាប់ចោទឈ្មោះ [redacted] ភក្តី បានសុំប្រាក់ជនរងគ្រោះដោយដាក់លក្ខខណ្ឌនឹងយករូបថតអាក្រាតកាយរបស់ជនរងគ្រោះមកគំរាមដើម្បីឱ្យជនរងគ្រោះផ្ញើលុយមកឱ្យខ្លួនទៀតផង ដោយលើកទី១ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ ជនរងគ្រោះផ្ទេរប្រាក់ពីគណនីធនាគាររបស់ជនរងគ្រោះឈ្មោះ [redacted]LEN No.[redacted]42 ទៅកាន់គណនីធនាគាររបស់ជនជាប់ចោទឈ្មោះ [redacted]XDEY No.[redacted] ទឹកប្រាក់ចំនួន ៣០០$ (បីរយដុល្លារអាមេរិក) ដែលមានលេខកូដប្រតិបត្តិការ [redacted], លើកទី២ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ជនរងគ្រោះផ្ទេរប្រាក់ពីគណនីរបស់ជនរងគ្រោះឈ្មោះ [redacted]LEN No.[redacted] ទៅកាន់គណនីធនាគាររបស់ជនជាប់ចោទឈ្មោះ [redacted]XDEY No.[redacted] ទឹកប្រាក់ចំនួន ១៧៥$ (មួយរយចិតសិបប្រាំដុល្លារអាមេរិក) ដែលមានលេខកូដប្រតិបត្តិការ

[redacted], លើកទី៣ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ ជនរងគ្រោះបានផ្ទេរប្រាក់ពីគណនីធនាគាររបស់ជនរងគ្រោះឈ្មោះ [redacted] LEN No.[redacted] ទៅកាន់គណនីធនាគាររបស់ឈ្មោះ [redacted] RIYA No.[redacted] ដែលជាមិត្តភក្តិរបស់ជនរងគ្រោះ ទឹកប្រាក់ចំនួន ២០០$ (ពីររយដុល្លារអាមេរិក) ដែលមានលេខកូដប្រតិបត្តិការ [redacted] ហើយមិត្តភក្តិរបស់ជនរងគ្រោះបានផ្ញើបន្តទៅកាន់ជនជាប់ចោទ និងលើកទី៤ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ ជនរងគ្រោះបានផ្ទេរប្រាក់ពីគណនីធនាគាររបស់ជនរងគ្រោះឈ្មោះ [redacted] LEN No. [redacted] ទៅកាន់គណនីធនាគាររបស់ជនជាប់ចោទឈ្មោះ [redacted] KDEY No.[redacted] ទឹកប្រាក់ចំនួន ២៥០$ (ពីររយហាសិបដុល្លារអាមេរិក) ដែលមានលេខកូដប្រតិបត្តិការ [redacted]។ ដោយសាររងនូវសម្ពាធផ្លូវចិត្តខ្លាំងពេក ជនរងគ្រោះក៏បានសម្រេចចិត្តទាក់ទងទៅកាន់គណនីហ្វេសប៊ុករបស់ក្រសួងកិច្ចការនារី ដើម្បីស្វែងរកអន្តរាគមន៍ផ្នែកផ្លូវច្បាប់។ ក្រោយពីទទួលបានការស្នើសុំជំនួយពីជនរងគ្រោះ ក្រសួងកិច្ចការនារី និងអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ បានសហការគ្នា រហូតឈានដល់ធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ភក្តី នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ចំណុចស្ថានីយ៍ប្រេងឥន្ធនៈភីធីធី ផ្លូវជាតិលេខ៦អា ភូមិ[redacted] [redacted] [redacted] ខេត្តសៀមរាប យកមកសាកសួរ និងកសាងសំណុំរឿងបញ្ជូនមកកាន់សាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធីច្បាប់។

-បានឃើញ របាយការណ៍សំយោគលេខ ១១៧/២០ រ.ប.ក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្សក្នុងប្រទេស។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៦១៣០ អ.យ.ផ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៧៨៧ អ.យ.ផ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៩៩៧ "ឆ" ដ.ជ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ [redacted] ភក្តី បានឆ្លើយថា៖ កាលពីថ្ងៃខែមិនចាំ ចុងឆ្នាំ២០១៩ ខ្លួនបានស្គាល់គ្នាជាមួយឈ្មោះ [redacted] ឡែន តាមរយៈបណ្តាញសង្គម និងបានរស់នៅជាមួយគ្នានៅក្នុងខុនដូរយៈពេល០៦ខែ និងបានទំនុកបម្រុងឱ្យឈ្មោះ[redacted] ឡែន បានរៀនសូត្រ។ លុះនៅអំឡុងខែមករា ឆ្នាំ២០២០ ឈ្មោះ[redacted] ឡែន បានជាប់ទៅធ្វើការនៅប្រទេសជប៉ុន ហើយខ្លួននិងឈ្មោះ [redacted] ឡែន បានទូរស័ព្ទទាក់ទងគ្នាជាធម្មតា និងបានថតរូបអាក្រាតតាមរយៈScreenshot ហើយរូបថតនេះគឺថតនៅពេលដែល [redacted] ឡែនបានទៅដល់ប្រទេសជប៉ុន។ រូបថតទាំងនេះគឺពួកខ្លួនទាំងពីរនាក់ជាអ្នកថត ដោយលើកទី១ រូបខ្លួនជាអ្នកថត និងលើកទី២ ឈ្មោះ [redacted] ឡែន ជាអ្នកថតវិញម្តង។ កន្លងមកឈ្មោះ [redacted] ឡែន បានផ្ញើលុយមកឱ្យខ្លួនចំនួនបីលើក មានទឹកប្រាក់សរុបប្រហែល ១.០០០ ដុល្លារ ដែលក្នុងនោះនៅលើកទី១ សម្រាប់ជាកាដូថ្ងៃកំណើត លើកទីពីរសម្រាប់ដោះស្រាយជីវភាពនៅពេលអត់ការងារធ្វើសម័យកូវីដ និងលើកទីបីខ្លួនមិនបានចាំទេ។ ក្រោយមកទៀតនៅពេលដែលLaptop របស់ខ្លួនខូច ខ្លួនក៏បានទាក់ទងទៅឈ្មោះ [redacted] ឡែន ដោយបានសុំលុយមួយចំនួនដើម្បីទុកជួសជុលLaptop ប៉ុន្តែឈ្មោះ [redacted] ឡែន មិនព្រមឱ្យ ពេលនោះខ្លួនបានគំរាមថា បើមិនឱ្យលុយទេប្រយ័ត្នខ្មាសគេ តែខ្លួនមិនបានបង្ហោះរូបថតអាក្រាតនោះទេ គ្រាន់តែបានផ្ញើរូបភាពតាមរយៈMessenger ឱ្យគ្នាទៅវិញទៅមក ហើយក្រោយមកខ្លួនក៏បានជ្រុះទូរស័ព្ទនោះបាត់ទៅនៅមុំស្ទឹងមានជ័យ។

ក្រឡាបញ្ជីអានពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡែន ដែលមានខ្លឹមសារថា៖ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ខ្លួនបានស្រឡាញ់គ្នាជាមួយឈ្មោះ [redacted] ភក្តី អាយុប្រហែល១៩ឆ្នាំ មុខរបរអ្នកចាក់ភ្លេង តាមរយៈហ្វេសប៊ុក ហើយបានរស់នៅដូចជាប្តីប្រពន្ធ ហើយឈ្មោះ [redacted] ភក្តី បានលួចថតវីដេអូ និងរូបភាពអាសអាភាសរបស់ខ្លួន តែខ្លួនមិនបានដឹងខ្លួននោះទេ។ នៅអំឡុងខែសីហា ឆ្នាំ២០១៩ ខ្លួនបានចូលរៀនភាសាជប៉ុន ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន ដំបូងទំនាក់ទំនងខ្លួនជាមួយឈ្មោះ [redacted] ភក្តី បានសុំប្រាក់ពីខ្លួនតែខ្លួនមិនព្រម ទើបឈ្មោះ [redacted] ភក្តី បានបង្ហាញរូបអាក្រាតកាយរបស់ខ្លួនកាលពីខ្លួនរស់នៅជាមួយគ្នា ហើយបានដាក់លក្ខខណ្ឌជាច្រើនឱ្យខ្លួនធ្វើតាមដូចជា មិនឱ្យខ្លួនទាក់ទងនឹងអ្នកជុំវិញខ្លួន មិនឱ្យទិញរបស់របរប្រើប្រាស់ដែលមិនបានឱ្យឈ្មោះ [redacted] ភក្តី ដឹង ពេលឪពុកម្តាយបងប្អូនទាក់ទងមកត្រូវសុំឈ្មោះ [redacted] ភក្តី ជាមុនទើបអាចនិយាយបាន ហើយពេលនិយាយចប់ត្រូវរៀបរាប់ថានិយាយអ្វីខ្លះជាមួយឪពុកម្តាយ នៅម៉ោង១០និង០០នាទី ពេលយប់ម៉ោងនៅប្រទេសជប៉ុន ជារៀងរាល់ថ្ងៃពេលចូលងូតទឹក ត្រូវនិយាយវីដេអូខលទៅឈ្មោះ [redacted] ភក្តី តាមរយៈហ្វេសប៊ុក ដើម្បី

ឱ្យឈ្មោះ [redacted] ភក្តី ឃើញខ្លួនកន្លែងដែលឈ្មោះ [redacted] ភក្តី ចង់ឃើញ ហើយឈ្មោះ [redacted] ភក្តី បានលួចថតវីដេអូពេលខ្លួនងូតទឹក។ ខ្លួនត្រូវផ្ញើប្រាក់ឱ្យទៅឈ្មោះ [redacted] ភក្តី ជារៀងរាល់ខែ បើមិនធ្វើតាមទេឈ្មោះ [redacted] ភក្តី និងបង្ហោះរូបភាពអាក្រាតកាយរបស់ខ្លួនទៅលើបណ្តាញសង្គមហ្វេសប៊ុកជាមិនខាន។ ខ្លួនមិនមានជម្រើសនោះទេ ទើបសម្រេចចិត្តធ្វើតាមឈ្មោះ [redacted] ភក្តី ខ្លួនបានផ្ញើប្រាក់ជាច្រើនលើកទៅឱ្យឈ្មោះ [redacted] ភក្តី លើកដំបូងគ្មានការគំរាមកំហែងទេចំនួន ៤០០$ (បួនរយដុល្លារអាមេរិក) និងចំនួន ២១២.០០០៛ (ពីរសែនមួយម៉ឺនពីរពាន់រៀល) តាមរយៈមិត្តភក្តិរបស់ខ្លួន ដែលបានផ្ញើ បន្តតាមរយៈវីងវេរលុយទៅទូរស័ព្ទរបស់ឈ្មោះ [redacted] ភក្តី លេខ ០១៥ ៣១ ៩៨ ២៨។ ក្រោយមកទៀតខ្លួនមិនព្រមផ្ញើប្រាក់ឱ្យ ទើបឈ្មោះ [redacted] ភក្តី បានគំរាមកំហែងបង្ហោះរូបភាពអាក្រាតកាយរបស់ខ្លួន ទើបធ្វើឱ្យខ្លួនយល់ព្រមលើកទី១ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ៦និង៤៥នាទី រសៀល ខ្លួនបានផ្ទេរលុយពីគណនីធនាគាររបស់ខ្លួនឈ្មោះ [redacted]LEN No.[redacted] ចូលគណនីធនាគាររបស់ឈ្មោះ [redacted] ភក្តី ឈ្មោះ [redacted]KDEY No[redacted] ដោយផ្ទាល់ ចំនួនទឹកប្រាក់ ៣០០$ (បីរយដុល្លារអាមេរិក) ដែលមានលេខកូដប្រតិបត្តិការ [redacted], លើកទី២ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង៦និង១៩នាទីរសៀល ខ្លួនបានផ្ទេរប្រាក់ពីគណនីធនាគាររបស់ខ្លួនឈ្មោះ [redacted]LEN No.[redacted] ចូលគណនីធនាគាររបស់ឈ្មោះ [redacted] ភក្តី ឈ្មោះ [redacted]KDEY No.[redacted] ដោយផ្ទាល់មានចំនួនទឹកប្រាក់ ១៧៥$ (មួយរយចិតសិបប្រាំដុល្លារអាមេរិក) ដែលមានលេខកូដប្រតិបត្តិការ [redacted], លើកទី៣ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង៤និង០៨នាទីរសៀល ខ្លួនបានផ្ទេរប្រាក់ពីគណនីធនាគាររបស់ខ្លួនឈ្មោះ [redacted] LEN No.[redacted] ចូលគណនីធនាគាររបស់ឈ្មោះ [redacted] ចរិយា មានឈ្មោះ [redacted]KRIYA No.[redacted] មិត្តភក្តិរបស់ខ្លួន ដែលមានលេខកូដប្រតិបត្តិការ [redacted] ហើយមិត្តភក្តិរបស់ខ្លួនបានផ្ញើប្រាក់បន្តចំនួន ២០០$ (ពីររយដុល្លារអាមេរិក) ទៅឈ្មោះ [redacted] ភក្តី, លើកទី៤ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង១និង១៥នាទីរសៀល ខ្លួនបានផ្ទេរប្រាក់ពីគណនីធនាគារឈ្មោះ [redacted]LEN No.[redacted] ចូលគណនីធនាគាររបស់ឈ្មោះ [redacted] ភក្តី ឈ្មោះ [redacted]KDEY No.[redacted] ដោយផ្ទាល់មានទឹកប្រាក់ចំនួន ២៥០$ (ពីររយហាសិបដុល្លារអាមេរិក) ដែលមានលេខកូដប្រតិបត្តិការ [redacted]។ ដោយសារតែមានការរងសម្ពាធផ្លូវចិត្តជាខ្លាំង ទើបខ្លួនសម្រេចចិត្តទាក់ទងទៅកាន់ផេកហ្វេសប៊ុករបស់ក្រសួងកិច្ចការនារី ដើម្បីស្វែងរកអន្តរាគមន៍ផ្នែកច្បាប់។ នៅក្នុងរឿងនេះខ្លួនសុំទាមទារសំណងការខូចខាត និងសំណងជំងឺចិត្តពីឈ្មោះ ហែម ភក្តី ចំនួន ២.៥០០$ (ពីរពាន់ប្រាំរយដុល្លារអាមេរិក)។

តំណាងក្រសួងកិច្ចការនារីឈ្មោះ [redacted] បណ្ឌុល បានឆ្លើយបំភ្លឺថា នៅខែកញ្ញា ឆ្នាំ២០២០ ខ្លួនបានទទួលការស្នើសុំអន្តរាគមន៍និងផ្តល់កិច្ចការពារពីស្ត្រីពលករទេសន្តរប្រវេសន៍កំពុងរស់នៅ និងធ្វើការនៅប្រទេសជប៉ុនតាមហ្វេសប៊ុកផេកផ្លូវការ របស់ក្រសួងកិច្ចការនារី និងតាមប្រព័ន្ធតេឡេក្រាមផ្ទាល់ខ្លួនរបស់ខ្លួន។ ស្ត្រីរងគ្រោះឈ្មោះ [redacted] ខ្សែន ដែលជាពលកររស់នៅប្រទេសជប៉ុន បានប្តឹងមកក្រសួងកិច្ចការនារី ថាត្រូវបានអតីតសង្សាររបស់គាត់ឈ្មោះ [redacted] ភក្តី (រស់នៅស្រុកខ្មែរ) គំរាមកំហែងបង្ហោះរូបភាពអាក្រាត, វីដេអូអាសអាភាស (នៅស្រុកខ្មែរ និងជប៉ុន) ដើម្បីទាមទារប្រាក់ក្នុងន័យជាថ្នូរមិនផ្សព្វផ្សាយរូបភាព និងវីដេអូអាសអាភាសទាំងនេះលើបណ្តាញសង្គម សរុបជាទឹកប្រាក់ដែលជនរងគ្រោះបានផ្ញើមកឱ្យជនជាប់ចោទចំនួន ៩២៥$ (ប្រាំបួនរយម្ភៃប្រាំដុល្លារអាមេរិក)។ នៅមុនថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ ជនរងគ្រោះឈ្មោះ [redacted] ខ្សែន បានពឹងពាក់ឱ្យក្រសួងកិច្ចការនារីជួយរៀបចំពាក្យប្តឹងជូនគាត់។ លុះដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ ជនរងគ្រោះឈ្មោះ [redacted] ខ្សែន បានទទួលសេចក្តីព្រាងពាក្យប្តឹងពីក្រសួងកិច្ចការនារីតាមរយៈសារអេឡិចត្រូនិច (តេឡេក្រាម) និងបានផ្តិតមេដៃលើពាក្យប្តឹង រួចផ្ញើតាមរយៈប្រៃសណីយ៍មកក្រសួងកិច្ចការនារី។ បន្ទាប់មកក្រសួងកិច្ចការនារីបានទទួលរាល់ឯកសារសន្ទនា និងសារសំឡេង (គ្មានរូបភាព និងវីដេអូអាសអាភាស) តាមរយៈហ្វេសប៊ុករបស់ជនរងគ្រោះមកផេកក្រសួងកិច្ចការនារី (Inbox) និងតេឡេក្រាមផ្ទាល់ខ្លួនរបស់ខ្លួន រួចខាងខ្លួនបានប្រមូលភស្តុតាងដែលជនរងគ្រោះផ្ញើមកទាំងអស់ មានសារសំឡេង កិច្ចសន្ទនា និងឯកសារបញ្ជាក់អត្តសញ្ញាណដាក់ចូលក្នុងយូអេសប៊ី (USB) រួចហើយខាងក្រសួងកិច្ចការនារីបានជួយសម្របសម្រួលរៀបចំលិខិតស្នើសុំកិច្ចអន្តរាគមន៍ដោយភ្ជាប់ពាក្យប្តឹង និងUSBទៅអគ្គស្នងការនគរបាលជាតិដើម្បីកសាងសំណុំរឿងមកសាលាដំបូងរាជធានីភ្នំពេញ។

ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ៣៩៣១ រ.វ.ត ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន[1]៖

-ទូរស័ព្ទដៃម៉ាកអាយហ្វូន (IPHONE 6S) ពណ៌ប្រផេះចំនួន០១គ្រឿង (មិនដំណើរការ)

(1).ឯកសារលេខ ៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-កុំព្យូទ័រយួរដៃ Mac Book Pro (ក្នុងកំណត់ហេតុប្រគល់ជនសង្ស័យសរសេរថា Mac Book Pro2021 ប៉ុន្តែក្នុងរបាយការណ៍សំយោគសរសេរថា Mac Book Pro 2010) ពណ៌ទឹកប្រាក់ចំនួន ០១គ្រឿង (មិនដំណើរការ)។

**សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីតំណាងឱ្យជនរងគ្រោះ និងជាដើមបណ្តឹង**

លោកស្រីមេធាវី [redacted] ស៊ីវ៉ន បានធ្វើសេចក្តីសន្និដ្ឋានថា តាមរយៈការសួរដេញដោលឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន។ នៅពេលរួមភេទជាមួយគ្នាជនជាប់ចោទមានចេតនាទុច្ចរិតគិតទុកជាមុន មុនពេលរួមភេទជាមួយជនរងគ្រោះ ដោយត្រៀមកាមេរ៉ាដើម្បីថតពេលរួមភេទដោយគ្មានការអនុញ្ញាត និងមិនឱ្យជនរងគ្រោះបានដឹង។ ក្រោយមកទៀតបានគំរាម ដោយយករូបភាពមកបង្ហោះដើម្បីទារប្រាក់ពីជនរងគ្រោះ តាមអង្គហេតុ និងអង្គច្បាប់ យោងតាមមាត្រា ៣០២ មត្រា៣៧២ និងមាត្រា៣៧៣ នៃក្រមព្រហ្មទណ្ឌ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភក្តី ដូច្នេះសូមស្នើឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឱ្យបានធ្ងន់ធ្ងរ។

**សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ**

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា កាលពីអំឡុងឆ្នាំ២០២០ នៅលើបណ្តាញសង្គមពិតជាមានករណីប៉ះពាល់ដល់សិទ្ធិខាងរូបភាពបុគ្គល និងគំរាមកំហែងហែកកេរ្តិ៍ ប្រាកដមែន ដូចលោកស្រីមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ បានលើកឡើង និងចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ភក្តី ថាពិតជាបាន Call Video Chat និងថត Screenshot រូបភាពអាសអាភាសជាមួយគ្នាប្រាកដមែន ហើយជាមួយគ្នានេះដែរជនជាប់ចោទបានសារភាពថា ខ្លួនពិតជាបានគំរាមកំហែងទៅលើជនរងគ្រោះ ដើម្បីឱ្យជនរងគ្រោះបំពេញនូវបំណងរបស់ខ្លួនដោយលើកហេតុផលនូវការគំរាមផ្សេងៗ ក៏ដូចជាការបង្ហាញរូបភាពអាសអាភាសដែលខ្លួនបានថតផងដែរ ដូច្នេះតំណាងអយ្យការនៅតែរក្សាបទចោទដូចក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

លោកមេធាវី [redacted] សុខា បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា កូនក្តីរបស់ខ្លួនបានថតរូបភាពប្រាកដមែន ប៉ុន្តែមិនបានបង្ហោះរូបភាពជាសាធារណៈទេ ដូច្នេះស្នើសុំឱ្យតុលាការជួយរកយុត្តិធម៌ដល់កូនក្តីខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់តំណាងក្រសួងកិច្ចការនារី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សាលាដំបូងរាជធានីភ្នំពេញ**

**យល់ឃើញថា**[2]

ក. តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៩៩៧ "ឆ" ដ.ដ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនទៅជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៨២៥៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងជនជាប់ចោទឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ១៩ឆ្នាំ ពីបទ ប៉ះពាល់ដល់សិទ្ធិខាងរូបភាពបុគ្គល និងគំរាមកំហែងហែកកេរ្តិ៍ ប្រព្រឹត្តនៅលើបណ្តាញសង្គម (Messenger របស់ជនរងគ្រោះ) កាលពីអំឡុងឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០២ មាត្រា៣៧២ និងមាត្រា៣៧៣ នៃក្រមព្រហ្មទណ្ឌ។[3]

ខ. អង្គហេតុកើតឡើងនៅលើបណ្តាញសង្គម(Messenger)ស្ថិតក្នុងរាជធានីភ្នំពេញ ហេតុនេះជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនៃសាលាដំបូងរាជធានីភ្នំពេញ។[4]

គ. អង្គហេតុកើតឡើង នៅក្នុងអំឡុងឆ្នាំ២០២០ បើគិតរហូតមកដល់ពេលនេះ មិនទាន់ផុតអាជ្ញាយុកាលនៃបទល្មើសទេ។[5]

---

(2).មាត្រា ៣២១, មាត្រា ៣២២ និងមាត្រា ៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(3). មាត្រា២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(4). មាត្រា២៨៩ និងមាត្រា២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(5). មាត្រា១០ និងមាត្រា១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ឃ. តាមរបាយការណ៍សំយោគលេខ ១១៧/២០ រ.ប.ក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្សក្នុងប្រទេសបានសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ[redacted] ភក្តី បានថតរូបភាពនិងវីដេអូអាក្រាតរបស់ជនរងគ្រោះឈ្មោ[redacted]ដាឡែន និងបានគំរាមកំហែងបង្ហោះរូបភាព និងវីដេអូអាក្រាតរបស់ជនរងគ្រោះទៅលើបណ្ដាញសង្គម ហើយម្យ៉ាងទៀតជនសង្ស័យពិតជាធ្លាប់បានទទួលប្រាក់ពីជនរងគ្រោះដែលផ្ទេរប្រាក់តាមគណនេយ្យធនាគារ ABA និងវីងវេរលុយ ប្រាកដមែន។[6]

ង. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ភក្តី បានឆ្លើយថា កាលពីថ្ងៃខែមិនចាំ នៅចុងឆ្នាំ២០១៩ ខ្លួនបានស្គាល់គ្នាជាមួយឈ្មោះ[redacted]ឡែន តាមរយៈបណ្ដាញសង្គម និងបានរស់នៅជាមួយគ្នានៅក្នុងខុនដូររយៈពេល០៦ខែ និងបានទំនុកបម្រុងឱ្យឈ្មោះ [redacted]ឡែន បានរៀនសូត្រ។ លុះនៅអំឡុងខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted]ឡែន បានជាប់ទៅធ្វើការនៅប្រទេសជប៉ុន ហើយខ្លួននិងឈ្មោះ [redacted]ឡែន បានទូរស័ព្ទទាក់ទងគ្នាជាធម្មតា និងបានថតរូបអាក្រាតតាមរយៈ Screenshot ហើយរូបថតនេះគឺថតនៅពេលដែលសុខដាឡែនបានទៅដល់ប្រទេសជប៉ុន។ រូបថតទាំងនេះគឺពួកខ្លួនទាំងពីរនាក់ជាអ្នកថត ដោយលើកទី១រូបខ្លួនជាអ្នកថត និងលើកទី២ ឈ្មោះ [redacted]ឡែន ជាអ្នកថតវិញម្ដង។ កន្លងមកឈ្មោះ [redacted]ឡែន បានផ្ញើលុយមកឱ្យខ្លួនចំនួនបីលើក មានទឹកប្រាក់សរុបប្រហែលចំនួន ១.000 ដុល្លារ ដែលក្នុងនោះនៅលើកទី១ សម្រាប់ជាកាដូថ្ងៃកំណើត លើកទីពីរសម្រាប់ដោះស្រាយជីវភាពនៅពេលអត់ការងារធ្វើសម័យកូវីដ និងលើកទីបីខ្លួនមិនបានចាំទេ។ ក្រោយមកទៀតនៅពេលដែលLaptop របស់ខ្លួនខូច ខ្លួនក៏បានទាក់ទងទៅឈ្មោះ [redacted]ឡែន ដោយបានសុំលុយមួយចំនួនដើម្បីទុកជួសជុលLaptop ប៉ុន្តែឈ្មោះ សុខដាឡែនមិនព្រមឱ្យ ពេលនោះខ្លួនបានគំរាមថា បើមិនឱ្យលុយទេប្រយ័ត្នខ្មាសគេ តែខ្លួនមិនបានបង្ហោះរូបថតអាក្រាតនោះជាសាធារណៈទេ ហើយក្រោយមកខ្លួនក៏បានជ្រុះទូរស័ព្ទនោះបាត់នៅម្ដុំស្ទឹងមានជ័យ។

ច. តាមពាក្យប្ដឹងរបស់ឈ្មោះ[redacted]ដាឡែន បានបញ្ជាក់ថា ខ្លួននិងឈ្មោះ[redacted] ភក្តី ពិតជាបានស្រឡាញ់គ្នា និងបានរស់នៅជាមួយគ្នាដូចប្ដីប្រពន្ធប្រាកដមែន នៅពេលដែលរស់នៅជាមួយគ្នាខ្លួនពុំបានដឹងថាឈ្មោះ [redacted] ភក្តី បានថតរូបអាក្រាត និងវីដេអូអាសអាភាសរបស់ខ្លួននោះទេ លុះពេលដែលខ្លួនត្រូវទៅធ្វើការនៅប្រទេសជប៉ុន ដោយខ្លួននិងឈ្មោះ [redacted] ភក្តី មានបញ្ហាជាមួយគ្នា ស្រាប់តែឈ្មោះ[redacted] ភក្តី បានបង្ហាញរូបភាពអាក្រាត និងវីដេអូអាសអាភាសរបស់ខ្លួនមកឱ្យខ្លួន ដោយបានគំរាមកំហែងថានឹងបង្ហោះរូបភាពនិងវីដេអូរទាំងនេះនៅលើបណ្ដាសង្គម ប្រសិនបើខ្លួនមិនព្រមផ្ញើលុយឱ្យទៅឈ្មោះ[redacted] ភក្តី ដោយមានការភ័យខ្លាចទើបខ្លួនបានផ្ញើប្រាក់ឱ្យទៅឈ្មោះ[redacted] ភក្តី ចំនួន៤លើក សរុបជាទឹកប្រាក់ចំនួន៩២៥$(ប្រាំបួនរយម្ភៃប្រាំដុល្លារអាមេរិក) តែដោយមានការទទួលរងនូវសម្ពាធផ្លូវចិត្តខ្លាំង ទើបខ្លួនសម្រេចចិត្តទាក់ទងទៅក្រសួងកិច្ចការនារីតាមរយៈហ្វេសប៊ុក ដើម្បីជួយអន្តរាគមន៍ផ្នែកផ្លូវច្បាប់ទៅលើឈ្មោះ[redacted] ភក្តី។

ឆ. តាមការបំភ្លឺរបស់អ្នកតំណាងក្រសួងកិច្ចការនារីឈ្មោះ[redacted]បណ្ឌូល បានបញ្ជាក់ថា នៅខែកញ្ញា ឆ្នាំ២០២០ ឈ្មោះ[redacted]ឡែន ដែលកំពុងតែធ្វើការនៅប្រទេសជប៉ុន បានទាក់ទងមកខ្លួន ដើម្បីឱ្យជួយសុំអន្តរាគមន៍និងផ្ដល់កិច្ចការពារពីស្ត្រីពលករទេសន្តរប្រវេសក៍ តាមរយៈហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួងកិច្ចការនារី និងតាមប្រព័ន្ធតេឡេក្រាមផ្ទាល់ខ្លួនរបស់ខ្លួន ដោយឈ្មោះ[redacted]ដាឡែន បានប្រាប់ថាត្រូវអតីតសង្សារនិងជាដៃគូស្និទ្ធស្នាលឈ្មោះ [redacted] ភក្តី គំរាមកំហែងហែកកេរ្តិ៍បង្ហោះរូបភាពអាក្រាត វីដេអូអាសអាភាស ជាថ្នូរមិនផ្សព្វផ្សាយរូបភាព និងវីដេអូអាសអាភាសទាំងនេះនៅលើបណ្ដាញសង្គម ដែលសរុបជាទឹកប្រាក់ដែលជនរងគ្រោះបានផ្ញើមកឱ្យជនជាប់ចោទចំនួន ៩២៥$ (ប្រាំបួនរយម្ភៃប្រាំដុល្លារអាមេរិក)។ លុះនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ ជនរងគ្រោះឈ្មោះ[redacted]ឡែន បានពឹងពាក់ឱ្យក្រសួងកិច្ចការនារីជួយរៀបចំពាក្យប្ដឹង និងភស្តុតាង ដែលជនរងគ្រោះបានផ្ញើមកទាំងអស់ មានសារសំឡេង កិច្ចសន្ទនា និងឯកសារបញ្ជាក់អត្តសញ្ញាណ ដាក់ចូលក្នុង USB ទើបខាងក្រសួងកិច្ចការនារីបានជួយសម្របសម្រួលរៀបចំលិខិតស្នើសុំអន្តរាគមន៍ដោយភ្ជាប់ពាក្យប្ដឹង និង USB ទៅអគ្គស្នងការនគរបាលជាតិដើម្បីកសាងសំណុំរឿងមកសាលាដំបូងរាជធានីភ្នំពេញតែម្ដង។

ជ. តាមកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ៣៩៣១ រ.វ.ត ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន៖

-ទូរស័ព្ទដៃម៉ាកអាយហ្វូន (IPHONE 6S) ពណ៌ប្រផេះ ចំនួន០១គ្រឿង (មិនប្រក្រតី)។

(6).(ឯកសារលេខ:១) របស់ការិយាល័យប្រឆាំងជួញដូរមនុស្សក្នុងប្រទេស។

-កុំព្យូទ័រយួរដៃ Mac Book Pro (ក្នុងកំណត់ហេតុប្រគល់ជនជាប់ចោទសរសេរថា Mac Book Pro2021 ប៉ុន្តែក្នុងរបាយការណ៍សំយោគសរសេរថា Mac Book Pro2010) ពណ៌ទឹកប្រាក់ចំនួន ០១គ្រឿង (មិនដំណើរការ)។

ឈ. តាមចម្លើយរបស់ជនជាប់ចោទ, តាមពាក្យប្តឹង, ចម្លើយរបស់សាក្សី, របាយការណ៍សំយោគរបស់សមត្ថកិច្ច និងភស្តុតាងមួយចំនួនទៀត មានភាពស៊ីសង្វាក់គ្នា ដែលអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ភក្តិ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ ប្រាកដមែន។

ញ. អំពើដែលជនជាប់ចោទឈ្មោះ [redacted] ភក្តិ បានធ្វើសកម្មភាពលួចថតរូបភាពរបស់ជនរងគ្រោះដើម្បីគំរាមកំហែងហែកកេរ្តិ៍ក្នុងគោលបំណងយកប្រាក់ពីជនរងគ្រោះនេះ បើផ្អែកតាមធាតុនីត្យានុកូល គឺស្របទៅនឹងធាតុផ្សំនៃបទល្មើស ប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល និងគំរាមកំហែងហែកកេរ្តិ៍ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០២ មាត្រា៣៧២ ចំណុចទី ៤ និងមាត្រា៣៧៣ នៃក្រមព្រហ្មទណ្ឌ។

-មាត្រា ៣០២ នៃក្រមព្រហ្មទណ្ឌ បានចែងពី និយមន័យនៃការប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល គឺជាអំពើថតរូបភាពនៃបុគ្គលនៅក្នុងទីកន្លែងឯកជន ដោយគ្មានការព្រមព្រៀងពីបុគ្គលនេះទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។

-មាត្រា ៣៧២ ចំណុចទី ៤ នៃក្រមព្រហ្មទណ្ឌ បានចែងពី និយមន័យនៃការគំរាមកំហែងហែកកេរ្តិ៍ គឺជាអំពើប្រព្រឹត្តដោយគំរាមកំហែងបើកកកាយ ឬចម្លាក់កំហុសទៅលើអំពើដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬ ការរាប់អាន ដើម្បីទទួលបាននូវការប្រគល់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ។

-មាត្រា ៣៧៣ បានចែងអំពីទោសដែលត្រូវអនុវត្តចំពោះអំពើគំរាមកំហែងហែកកេរ្តិ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

ដ. ជនជាប់ចោទឈ្មោះ [redacted] ភក្តិ ភេទប្រុស អាយុ១៨ឆ្នាំ ជានីតិជន មានស្មារតីល្អមានការយល់ដឹងគ្រប់គ្រាន់ក្នុងការពិចារណា ព្រមទាំងបានដឹងយ៉ាងច្បាស់នូវអំពើរបស់ខ្លួនថាជាអំពើខុសច្បាប់ ហើយក៏មិនមានសញ្ញាណណាមួយបញ្ជាក់ថាជននេះមានវិបល្លាសស្មារតីអ្វីដែរ។[7]

ឋ. អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ភក្តិ ភេទប្រុស អាយុ១៨ឆ្នាំ បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ពិសេសប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះផ្ទាល់ ដែលច្បាប់តម្រូវឱ្យផ្តន្ទាទោស។

ឌ. កំណត់ហេតុទទួលវត្ថុចាប់យក(១)លេខ ៣៩៣១ រ.វ.ត ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ រួមមាន ទូរស័ព្ទដៃម៉ាកអាយហ្វូន (IPHONE 6S) ពណ៌ប្រផេះ ចំនួន០១គ្រឿង (មិនប្រក្រតី) និងកុំព្យូទ័រយួរដៃ Mac Book Pro (ក្នុងកំណត់ហេតុប្រគល់ជនជាប់ចោទសរសេរថា Mac Book Pro2021 ប៉ុន្តែក្នុងរបាយការណ៍សំយោគសរសេរថា Mac Book Pro2010) ពណ៌ទឹកប្រាក់ ចំនួន០១គ្រឿង (មិនដំណើរការ) ជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូស ផ្អែកតាមមាត្រា៦២, ៦៣នៃក្រមព្រហ្មទណ្ឌ។

ឍ. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡែន បានទាមទារសំណងជំងឺចិត្តនិងការខូចខាត ពីជនជាប់ចោទឈ្មោះ [redacted] ភក្តិ ចំនួន ២.៥០០$ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក ការស្នើសុំនេះគប្បីតុលាការលើកយកមកពិចារណា។

ណ. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៧៨៧ អ.យ.ថ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ទុកជាបានការដដែល និងស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ការស្នើសុំនេះគប្បីតុលាការលើកយកមកធ្វើការពិចារណា។

ត. លោកស្រីមេធាវី [redacted] ស៊ីវ៉ន ជាមេធាវីតំណាងឱ្យជនរងគ្រោះនិងជាដើមបណ្តឹងបានធ្វើសេចក្តីសន្និដ្ឋានថា សុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ភក្តិឱ្យបានធ្ងន់ធ្ងរបំផុត ការស្នើសុំនេះគប្បីតុលាការលើកយកមកពិចារណា។

ថ. លោកមេធាវី [redacted] សុខា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន ដោយស្នើសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យកូនក្តីរបស់ខ្លួនផង ការស្នើសុំនេះគប្បីតុលាការលើកយកមកពិចារណា។

ទ. ជនជាប់ចោទឈ្មោះ [redacted] ភក្តិ បានសំណូមពរសូមឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោស ដើម្បីឱ្យខ្លួនឆាប់បានទៅជួយការងារសង្គមវិញ ការស្នើសុំនេះគប្បីតុលាការលើកយកមកពិចារណា។

---

(7).មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ។

មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ១៨ឆ្នាំ ពីបទ ប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល និងគំរាមកំហែងហែកកេរ្តិ៍ ប្រព្រឹត្តនៅលើបណ្តាញសង្គម (Messenger របស់ជនរងគ្រោះ) កាលពីអំឡុងឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០២ មាត្រា៣៧២ ចំណុចទី៤ និងមាត្រា៣៧៣ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះ សម្រេច**

១.ផ្តន្ទាទោសឈ្មោះ[redacted] ភក្តី ភេទប្រុស អាយុ១៨ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន៣(បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន៤.០០០.០០០(បួនលាន)រៀល ពីបទ ប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល និងគំរាមកំហែងហែកកេរ្តិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០២ មាត្រា៣៧២ ចំណុចទី៤ និងមាត្រា៣៧៣ នៃក្រមព្រហ្មទណ្ឌ។[8]

**២.វត្ថុចាប់យកមាននៅក្នុងកំណត់ហេតុលេខ ៣៩៣១ រ.វ.ត ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០៖**

**២.១.ត្រូវរឹបអូសចូលជាសម្បត្តិរដ្ឋនូវមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើសដូចខាងក្រោម៖**[9]

២.១.១.ទូរស័ព្ទម៉ាកអាយហ្វូន (IPHONE 6S) ពណ៌ប្រផេះ ចំនួន០១គ្រឿង (មិនប្រក្រតី)។

២.១.២.កុំព្យូទ័រយួរដៃ Mac Book Pro (ក្នុងកំណត់ហេតុប្រគល់ជនជាប់ចោទសរសេរថា Mac Book Pro2021 ប៉ុន្តែក្នុងរបាយការណ៍សំយោគសរសេរថា Mac Book Pro2010) ពណ៌ទឹកប្រាក់ចំនួន ០១គ្រឿង (មិនដំណើរការ)។

៣.បង្គាប់ឱ្យឈ្មោះ[redacted] ភក្តី សងសំណងរដ្ឋប្បវេណី និងសំណងជំងឺចិត្តឱ្យទៅឈ្មោះ[redacted] ជាទឹកប្រាក់ចំនួន១០.០០០.០០០(ដប់លាន)រៀល។[10]

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ ពេលព្រឹក ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] ភក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ ពេលព្រឹក និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០២១ ពេលព្រឹក។[11]

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។[12]

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា លោក [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា លោក [redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃព្រហស្បតិ៍ ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
ថ្ងៃព្រហស្បតិ៍ ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១
**ចៅក្រមជំនុំជម្រះ**
[redacted]

---

(8).មាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(9).មាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

(10).មាត្រា៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(11).មាត្រា៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(12).មាត្រា៣៧៥, មាត្រា ៣៨១ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។